**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ៣៧៣ សរណ

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ មិរា ឆ្នាំ២០១៧

**ជម្រាបមក**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**<u>កម្មវត្ថុ</u>** ÷ ស្តីពីការអនុវត្តគោលការណ៍ និងនីតិវិធីចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលបានទៅឈរឈ្មោះជាបេក្ខជនពេញសិទ្ធិ ឬបេក្ខជនបម្រុងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

**<u>យោង</u>** ÷
- ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ព្រះរាជក្រមលេខ ជស/រកម/១១៩៧/ ០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- ប្រកាសលេខ ១៨៨៤ ប្រក. ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- សេចក្តីណែនាំលេខ ០១១ សណន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សេចក្តីណែនាំលេខ ០២២ សណន ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមថា បន្ទាប់ពីដំណើរការចុះឈ្មោះបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ខាងមុខ ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា មានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌក្នុងមុខតំណែងដែលមកពីគណបក្សមួយចំនួនបានទៅឈរឈ្មោះជាបេក្ខជនពេញសិទ្ធិ ឬបេក្ខជនបម្រុងរបស់គណបក្សមួយទៀត ដែលមិនមែនជាគណបក្សនយោបាយដែលខ្លួនបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៃគណបក្សនយោបាយនោះ។

ពាក់ព័ន្ធនឹងបញ្ហាខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីការអនុវត្តគោលការណ៍ និងនីតិវិធីចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលបានទៅឈរឈ្មោះជាបេក្ខជនពេញសិទ្ធិ ឬបេក្ខជនបម្រុងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ដូចខាងក្រោម៖

**១**-អនុលោមតាមមាត្រា១៥ និងមាត្រា១៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ បានចែងថា " ប្រជាពលរដ្ឋខ្មែរម្នាក់ មិនអាចជាសមាជិកគណបក្សនយោបាយលើសពីមួយក្នុងពេលតែមួយបានទេ។

ក្នុងករណីដែល បុគ្គលមួយរូបចូលជាសមាជិកគណបក្សនានាយ៉ាងច្រើន សមាជិកភាពក្នុងគណបក្សនយោបាយចុងក្រោយ ត្រូវចាត់ទុកជាបានការ។ ទន្ទឹមនោះ សមាជិកគណបក្សនយោបាយត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនក្នុងករណីបានលាឈប់ ឬបានបោះបង់សមាជិកភាពនៃគណបក្សនយោបាយរបស់ខ្លួន"។

ផ្អែកតាមបទប្បញ្ញត្តិខាងលើ ប្រសិនបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌរបស់គណបក្សមួយ បានទៅឈរឈ្មោះជាបេក្ខជនពេញសិទ្ធិ ឬបេក្ខជនបម្រុងរបស់គណបក្សនយោបាយមួយផ្សេងទៀតនោះ សមាជិកភាពក្នុងគណបក្សនយោបាយចុងក្រោយត្រូវចាត់ទុកជាបានការ។ ដូច្នេះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌទាំងនោះ នឹងត្រូវបាត់បង់សមាជិកភាពពីគណបក្សនយោបាយដើមរបស់ខ្លួន ស្របតាមស្មារតីច្បាប់ស្តីពីគណបក្សនយោបាយ។ ទន្ទឹមនេះ ផ្អែកតាមមាត្រា១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងមាត្រា ២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការបាត់បង់សមាជិកភាពពីគណបក្សនយោបាយនឹងនាំឲ្យសាមីខ្លួនបាត់បង់សមាជិកភាពពីក្រុមប្រឹក្សាផងដែរ។

២-ក្នុងករណីពិនិត្យឃើញដូចក្នុងចំណុចទី១ខាងលើ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការណែនាំជាបន្ទាន់ដល់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី ឲ្យរៀបចំបែបបទ និងធ្វើសំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះ ស្របទៅតាមមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំង**សេចក្តីណែនាំ**ស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង**សេចក្តីណែនាំ**ស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣-ចំពោះសមាជិកក្រុមប្រឹក្សាដែលបានបាត់បង់សមាជិកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌហើយនោះ សាមីខ្លួននឹងមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាទៀតឡើយ។ ទន្ទឹមនេះ អង្គភាព ឬមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រង និងការបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សានោះ ត្រូវធ្វើការត្រួតពិនិត្យ និងចាត់វិធានការនានាពាក់ព័ន្ធនឹងការបើកប្រាក់ឧបត្ថម្ភរបស់សាមីខ្លួនស្របទៅតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការរាប់អានពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

( ដើម្បីជូនជ្រាបជាព័ត៌មាន )

- ឯកសារ កាលប្បវត្តិ